# សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

# Universal Declaration of Human Rights

អនុម័តនិងប្រកាសតាមសេចក្ដីសំរេចនៃមហាសន្និបាតលេខ ២១៧ A (III) ចុះនៅថ្ងៃទី ១០ ធ្នូ ១៩៤៨
Adopted and proclaimed by General Assembly resolution 217 A (III) of 10 December 1948

## បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់នូវសេចក្ដីថ្លៃថ្នូររបស់មនុស្សដែលមានតាំងពីកំណើត និង សិទ្ធិស្មើភាពគ្នានិងដែលមិនអាចដកហូតបានរបស់ពូជពង្សមនុស្សគ្រប់រូបគឺជាគ្រឹះនៃសេរីភាព, យុត្តិធម៌ និង សន្តិភាពក្នុងពិភពលោក ។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្សបាននាំអោយកើតមាននូវអំពើព្រៃផ្សៃសាហាវយង់ឃ្នងដែលជាទំនាស់យ៉ាងខ្លាំងដល់មនសិកាមេនុស្សជាតិ និងដោយហេតុថា មនុស្សដែលមានជីវិតរស់នៅក្នុងពិភពលោកត្រូវមាននូវសេរីភាពក្នុងការនិយាយស្ដី, ជំនឿ និង សេរីភាពផុតពីអំពើភេរវកម្មនិងភាពក្រីក្រតោកយ៉ាក ត្រូវបានប្រកាសថាជាសេចក្ដីប្រាថ្នាដ៏ឧត្តមបំផុតរបស់មនុស្សទូទៅ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលថា សិទ្ធិមនុស្សត្រូវតែមាននូវកិច្ចការពារដោយធម្មាធិបតេយ្យ ប្រសិនបើមនុស្សមិនត្រូវបានទទួលរងនូវការបង្ខិតបង្ខំអោយចាប់យកនូវគ្រឿងដោះបន្ទាល់ជាជំរើសចុងក្រោយដើម្បីបះបោរប្រឆាំងនឹងអំណាចផ្ដាច់ការនិងការគៀបសង្កត់ទេនោះ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ណាស់ដើម្បីលើកស្ទួយដល់ការពង្រីកនូវទំនាក់ទំនងជាមិត្តភាពរវាងប្រជាជាតិនានា ។

*ដោយយល់ឃើញថា* នៅក្នុងធម្មនុញ្ញ ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិបានប្រកាសសារជាថ្មីម្តងទៀតនូវជំនឿរបស់ខ្លួនទៅលើសិទ្ធិសំខាន់ៗ សេចក្តីថ្លៃថ្នូរ តម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ហើយប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិបានប្រកាសយ៉ាងប្តូរផ្តាច់ដើម្បីលើកស្ទួយវឌ្ឍនភាពសង្គម និងបទដ្ឋានដ៏ប្រសើរនៃការរស់នៅក្នុងសេរីភាពដ៏ទូលំទូលាយ ។

*ដោយហេតុថា* ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់បានសច្ចាធ្វើអោយបានសំរេចនូវការលើកស្ទួយការគោរពជាសកលចំពោះសិទ្ធិមនុស្ស និងការប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗទាំងឡាយ ។

*ដោយយល់ស្របថា* ការយល់ដឹងជាទូទៅនូវសិទ្ធិនិងសេរីភាពទាំងនេះមានសារសំខាន់ដ៏ធំធេងបំផុតដើម្បីធ្វើអោយបានទទួលយ៉ាងពេញលេញនូវការសច្ចាប្រណិធាននេះ,

***ដោយហេតុនេះ នៅពេលនេះ***

***មហាសន្និបាតប្រកាសថា:***

***សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*** គឺជាបទដ្ឋាននៃសេចក្តីសំរេចបានរួមគ្នាមួយសំរាប់ប្រជាពលរដ្ឋនិងប្រជាជាតិទាំងអស់ ទៅកាន់ទីបញ្ចប់មួយត្រង់ថា បុគ្គលគ្រប់ៗរូបនិងអង្គការសង្គមទាំងអស់ដែលរក្សាជាប់ក្នុងចិត្តជានិច្ចនូវសេចក្តីប្រកាសនេះ ត្រូវខិតខំប្រឹងប្រែងតាមរយៈការបង្រៀននិង អប់រំដើម្បីលើកស្ទួយការគោរពសិទ្ធិនិងសេរីភាពទាំងនេះ និងតាមរយៈវិធានការជាតិនិងអន្តរជាតិជាលំដាប់ៗទៅមុខ ដើម្បីធានាអោយបាននូវការទទួលស្គាល់និងការប្រតិបត្តិតាមជាសកលនិងប្រកបដោយប្រសិទ្ធិភាព ទាំងក្នុងចំណោមប្រជាពលរដ្ឋនានានៃរដ្ឋជាសមាជិកខ្លួនឯង ទាំងក្នុងចំណោមប្រជាពលរដ្ឋនានាដែលរស់នៅក្រោមដែនអំណាចច្បាប់របស់ខ្លួន ។

## មាត្រា ១

មនុស្សទាំងអស់កើតមកមានសេរីភាពនិងភាពស្មើៗគ្នាក្នុងសិទ្ធិនិងសេចក្ដីថ្លៃថ្នូរ។ មនុស្សគ្រប់រូបសុទ្ធតែមានវិចារណញ្ញាណនិងសតិសម្បជញ្ញៈ ហើយត្រូវប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីរាប់អានគ្នាជាបងប្អូន។

## មាត្រា ២

មនុស្សគ្រប់រូបមានសិទ្ធិនិងសេរីភាពគ្រប់បែបយ៉ាងទាំងអស់ ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ ដោយគ្មានការបែងចែកជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងៗទៀត, ប្រភពជាតិឬសង្គម ទ្រព្យសម្បត្តិ កំណើតឬឋានៈដទៃៗទៀតឡើយ។

បន្ថែមលើនេះទៀត មិនត្រូវធ្វើការបែងចែកណាមួយដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬឋានៈជាអន្តរជាតិនៃប្រទេស ឬដែនដីដែលបុគ្គលមួយរូបជាសមាជិកឡើយ ទោះប្រទេសនោះជាប្រទេសឯករាជ្យ ឬស្ថិតនៅក្រោមអាណត្តិគ្រប់គ្រង ឬមិនគ្រប់គ្រងដោយខ្លួនឯង ឬស្ថិតក្រោមការដាក់កំរិតដទៃៗណាមួយនៃអធិបតេយ្យភាពយ៉ាងណាក៏ដោយ ។

## មាត្រា ៣

បុគ្គលម្នាក់ៗត្រូវមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

## មាត្រា ៤

គ្មានជនណាម្នាក់ត្រូវជាប់ក្នុងភាពជាទាសករ ឬក្នុងភាពជាអ្នកបំរើគេឡើយ ហើយការជួញដូរទាសករក្នុងទម្រង់យ៉ាងណាក៏ដោយត្រូវហាមឃាត់។

## មាត្រា ៥

គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការធ្វើបាប ឬការដាក់ទណ្ឌកម្មយ៉ាងសាហាវឃោរឃៅ អមនុស្សធម៌ឬយ៉ាងថោកទាបឡើយ ។

## មាត្រា ៦

មនុស្សគ្រប់រូប មានសិទ្ធិអោយគេទទួលស្គាល់ខ្លួនថាជាបុគ្គលមួយរូបចំពោះមុខច្បាប់នៅគ្រប់ទីកន្លែងទាំងអស់ ។

## មាត្រា ៧

មនុស្សទាំងអស់មានភាពស្មើៗគ្នានៅចំពោះមុខច្បាប់ ហើយមានសិទ្ធិទទួលបាននូវកិច្ចការពារដោយច្បាប់ដោយស្មើៗគ្នាដោយគ្មានការរើសអើយណាមួយឡើយ ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវកិច្ចការពារខ្លួនស្មើៗគ្នាប្រឆាំងទល់នឹងការរើសអើងណាមួយដែលជាការរំលោភនូវសេចក្តីប្រកាសនេះ និងប្រឆាំងទល់នឹងការញុះញង់ណាមួយដែលនាំទៅមានការរើសអើង ។

## មាត្រា ៨

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវការដោះស្រាយដោយតុលាការជាតិដែលមានសមត្ថភាពចំពោះអំពើទាំងឡាយដែលរំលោភសិទ្ធិសំខាន់ៗរបស់ខ្លួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬដែលមានចែងនៅក្នុងច្បាប់ ។

## មាត្រា ៩

គ្មានបុគ្គលណាម្នាក់ត្រូវទទួលរងការចាប់ខ្លួន, ការឃុំឃាំងខ្លួន ឬនិរទេសខ្លួនតាមអំពើចិត្តបានឡើយ ។

## មាត្រា ១០

ក្នុងការធ្វើសេចក្តីសំរេចជាចុងក្រោយអំពីសិទ្ធិឬកាតព្វកិច្ចរបស់ខ្លួន និងនៅក្នុងការចោទប្រកាន់អំពីបទឧក្រិដ្ឋណាមួយមកលើខ្លួន បុគ្គលគ្រប់រូបមានសិទ្ធិមានភាពស្មើគ្នាយ៉ាងពេញលេញដើម្បីអោយមានសាវនាការសាធារណៈនិងត្រឹមត្រូវ ដែលធ្វើឡើងដោយតុលាការឯករាជ្យនិងមិនលំអៀង ។

## មាត្រា ១១

១. បុគ្គលណាដែលគេត្រូវចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិសំអាងថាខ្លួនជាជនគ្មានទោស រហូតដល់ពេលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាខ្លួនមានទោសអាស្រ័យទៅតាមច្បាប់ នៅក្នុងការជំនុំជំរះក្តីជាសាធារណៈ ដែលមានការធានាគ្រប់គ្រាន់សំរាប់បុគ្គលដើម្បីការពារខ្លួន ។

២. គ្មានបុគ្គលណាម្នាក់មានទោសពីបទព្រហ្មទណ្ឌចំពោះអំពើណាមួយ ឬការមិនប្រតិបត្តិតាមណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ជាតិ ឬអន្តរជាតិ នៅខណៈពេលដែលបទល្មើសបានប្រព្រឹត្តឡើង។ គ្មានទោសបញ្ញត្តិណាមួយត្រូវបានគេយកមកដាក់បង្ខំទៅលើជនណាម្នាក់ឱ្យធ្ងន់ជាងទោសបញ្ញត្តិដែលបានអនុវត្តន៏នៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌនោះបានប្រព្រឹត្តឡើយ ។

## មាត្រា ១២

គ្មានបុគ្គលណាម្នាក់ ត្រូវទទួលរងនូវការជ្រៀតជ្រែកតាមអំពើចិត្តក្នុងកិច្ចការសម្ងាត់ផ្ទាល់ខ្លួន, ក្នុងគ្រួសារ, លំនៅស្ថាន, ឬការឆ្លើយឆ្លង ឬវាយប្រហារទៅលើកិត្តិយសនិងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ បុគ្គលគ្រប់រូប មានសិទ្ធិទទួលបាននូវកិច្ចការពារខ្លួនដោយច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការវាយប្រហារទាំងនេះ។

## មាត្រា ១៣

១. បុគ្គលគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិមានទីលំនៅក្នុងព្រំដែននៃប្រទេសនិមួយៗ។

២. បុគ្គលគ្រប់រូបមានសិទ្ធិចាកចេញពីគ្រប់ប្រទេស រួមទាំងប្រទេសរបស់ខ្លួននិងមានសិទ្ធិត្រឡប់មកមាតុប្រទេសរបស់ខ្លួនវិញ។

## មាត្រា ១៤

១. បុគ្គលគ្រប់រូបមានសិទ្ធិស្វែងរក និងទទួលបាននូវសិទ្ធិជ្រកកោននៅក្នុងប្រទេសដទៃៗទៀត ក្នុងករណីណាដែលមានការធ្វើទុក្ខបុកម្នេញមកលើរូបខ្លួន។

២. សិទ្ធិសុំការជ្រកកោននេះនឹងមិនអាចលើកមកសំអាងបានទេ នៅក្នុងករណីណាដែលការធ្វើទុក្ខបុកម្នេញនោះកើតចេញពីបទល្មើសដែលពុំមែនជាបទល្មើសខាងនយោបាយ ឬដែលកើតចេញពីអំពើទាំងឡាយដែលផ្ទុយនឹងគោលបំណង និងគោលការណ៍របស់អង្គការសហប្រជាជាតិ។

## មាត្រា ១៥

១. បុគ្គលគ្រប់ៗរូបមានសិទ្ធិទទួលបាននូវសញ្ជាតិមួយ។

២. គ្មានបុគ្គលណាម្នាក់ត្រូវគេដកហូតសញ្ជាតិរបស់ខ្លួន ឬត្រូវបានគេបដិសេធចោលនូវសិទ្ធិផ្លាស់ប្តូរសញ្ជាតិរបស់ខ្លួន តាមអំពើចិត្តបានឡើយ។

## មាត្រា ១៦

១. បុរស និងស្ត្រីពេញវ័យគ្រប់រូប ដោយគ្មានការដាក់កំហិតល័ក្ខខ័ណ្ឌណាមួយអាស្រ័យលើពូជសាសន៍ សញ្ជាតិ ឬសាសនា មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារមួយ។ បុរស និងស្ត្រីមានសិទ្ធិស្មើៗគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ និងនៅពេលលែងលះគ្នា ។

២. អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមយ៉ាងពេញលេញ និងដោយសេរី ពីសំណាក់អនាគតគូស្វាមីនិងភរិយា ។

៣. គ្រួសារជាកត្តាពង្សធម្មជាតិ និងជាកត្តាពង្សគ្រឹះរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលបាននូវកិច្ចការពារពីសង្គមនិងរដ្ឋ ។

## មាត្រា ១៧

១. មនុស្សគ្រប់រូប មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ទោះជាបុគ្គលក្តី ឬជាសមូហភាពក្តី ។

២. គ្មានជនណាម្នាក់ ត្រូវគេដកហូតកម្មសិទ្ធិរបស់គេតាមតែអំពើចិត្តបានឡើយ ។

## មាត្រា ១៨

មនុស្សគ្រប់រូប មានសិទ្ធិនិងមានសេរីភាពខាងផ្លូវគំនិត ខាងផ្លូវសតិសម្បជញ្ញៈ និងខាងផ្លូវសាសនា ។ សិទ្ធិនេះ រាប់ទាំងសេរីភាពក្នុងការផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពក្នុងការសំដែងចេញនូវសាសនា ឬជំនឿតាមរយៈការបង្ហាត់បង្រៀន ការប្រតិបត្តិ ការគោរពបូជា ព្រមទាំងការប្រារព្ធពិធីសក្ការៈផ្សេងៗ ទោះតាមម្នាក់ឯងក្តី ឬរួមក្នុងសហគមន៍ជាមួយអ្នកឯទៀតក្តី និងទោះតាមសាធារណៈ ឬជាឯកជនក្តី ។

## មាត្រា ១៩

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពមានមតិ និងសេរីភាពក្នុងការសម្តែងមតិ ។ សិទ្ធិនេះរាប់ទាំងសេរីភាពក្នុងការប្រកាន់មតិ និងការសម្តែងមតិ ដោយគ្មានការជ្រៀតជ្រែក ព្រមទាំងសេរីភាពក្នុងការស្វែងរក, ការទទួល និងការផ្សព្វផ្សាយពតិមាន និងគំនិតនានា តាមរយៈប្រព័ន្ធឃោសនាណាមួយក៏ ដោយ និងដោយឥតគិតពីព្រំដែនអ្វីឡើយ ។

## មាត្រា ២០

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ និងធ្វើសមាគមដោយសន្តិវិធី ។

២. គ្មានជនណាម្នាក់ត្រូវគេបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ ។

## មាត្រា ២១

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាងទាំងឡាយ ដែលគេបានជ្រើសរើសដោយសេរី ។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបំរើការងារសាធារណៈនៃប្រទេសរបស់ខ្លួនស្មើៗ គ្នា ។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ត្រូវតែជាមូលដ្ឋានគ្រឹះនៃអាជ្ញាធររបស់រដ្ឋាភិបាល។ ឆន្ទៈនេះនឹងត្រូវបានសម្តែងចេញតាមរយៈការបោះឆ្នោតយ៉ាងទៀងទាត់តាមពេលកំណត់ និងពិតប្រាកដ ដែលនឹងត្រូវធ្វើជាសកល និងមានសិទ្ធិបោះឆ្នោតស្មើៗគ្នា ហើយត្រូវធ្វើតាមរយៈសន្លឹកឆ្នោតសំងាត់ ឬតាមទំរង់ការបោះឆ្នោតដោយសេរីណាមួយ ដែលមានតម្លៃស្មើ ។

## មាត្រា ២២

១, ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវសន្តិសុខសង្គម និងមានសិទ្ធិយល់ដឹងអំពីសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ ដែលជាសារៈ សំខាន់ចាំបាច់សំរាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈកិច្ចខិតខំរបស់ជាតិរដ្ឋនិមួយៗ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយស្របតាមអង្គការចាត់តាំង និងធនធាននៃរដ្ឋនិមួយៗ។

## មាត្រា ២៣

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ, មានសិទ្ធិជ្រើសរើសការងារ, និងមានសិទ្ធិធ្វើការងារក្នុងលក្ខណៈត្រឹមត្រូវ និងគួរពេញចិត្ត ព្រមទាំងមានសិទ្ធិទទួលបាននូវកិច្ចការពារទល់នឹងភាពឥតមានការងារធ្វើ ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នាសំរាប់ទង្វើការងារដូចគ្នា ដោយឥតមានការរើសអើងអ្វីឡើយ ។

៣. ជនដែលធ្វើការងារ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ត្រឹមត្រូវ និងគួរពេញចិត្ត ដើម្បីធានាជីវភាពរស់នៅរបស់គេនិងគ្រួសារគេ ឱ្យមាននូវតម្លៃនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវបានបំពេញបន្ថែមតាមមធ្យោបាយការពារផ្នែកសង្គមផ្សេងៗទៀត ប្រសិនបើមានការចាំបាច់ ។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើតសហជីព និងមានសិទ្ធិចូលជាសមាជិកនៃសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

## មាត្រា ២៤

មនុស្សគ្រប់រូប មានសិទ្ធិឈប់សំរាក និងលំហែរកំសាន្ត រាប់ទាំងការកំណត់ពេលម៉ោងធ្វើការសមហេតុសមផល ព្រមទាំងថ្ងៃបុណ្យឈប់សំរាកតាមកាលកំណត់ ដោយបានទទួលប្រាក់បៀវត្សរ៍ទៀតផង ។

## មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវជីវភាពគ្រប់គ្រាន់តាមបទដ្ឋាន សំរាប់សុខភាព និងសុខុមាលភាពរបស់គេ និងគ្រួសារគេ មានជាអាទិ៍ចំណីអាហារ សម្លៀកបំពាក់ លំនៅឋានការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត ព្រមទាំងសិទ្ធិទទួលបាននូវសន្តិសុខក្នុងពេលគ្មានការងារធ្វើ, ពេលមានជម្ងឺ, ពេលធ្លាក់ខ្លួនពិការ, ពេលប្តូរភាពជាមេម៉ាយ ឬពោះម៉ាយ, ពេលចាស់ជរា ឬការខ្វះខាតខាងជីវភាពដទៃៗទៀត ក្នុងកាលៈទេសៈដែលហួសពីភាពម្ចាស់ការរបស់គេ ។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលបាននូវការថែទាំ និងជួយទំនុកបំរុងពិសេស ។ គ្រប់កុមារទាំងអស់ ទោះកើតពីឪពុកម្តាយរៀបអាពាហ៍ពិពាហ៍និងគ្នាក្តី ឬមិនបានរៀបអាពាហ៍ពិពាហ៍ក្តី ត្រូវបានទទួលកិច្ចការពារខាងសង្គមកិច្ចដូចគ្នា ។

## មាត្រា ២៦

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលការអប់រំ ។ ការអប់រំត្រូវតែធ្វើឡើងដោយឥតគិតថ្លៃ យ៉ាងហោចណាស់សម្រាប់ការអប់រំថ្នាក់បឋម និងមូលដ្ឋាន ។ ការអប់រំជាន់ដំបូងត្រូវតែមានជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេកទេស និងខាងវិជ្ជាជីវៈ ត្រូវតែរៀបចំឱ្យមានជាទូទៅ ហើយការអប់រំ ថ្នាក់ឧត្តមត្រូវបើកឱកាសស្មើៗគ្នាឱ្យដល់មនុស្សគ្រប់រូបទាំងអស់ ដោយឈរលើមូលដ្ឋានគុណសម្បត្តិរបស់គេ ។

២. ការអប់រំត្រូវតែផ្តោតទៅរកការរីកចំរើនលូតលាស់យ៉ាងពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងឆ្ពោះទៅរកការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា ។ ការអប់រំនេះវាលើកស្ទួយដល់ការយល់ដឹង, ការអត់អោនអធ្យាស្រ័យគ្នា និងមិត្តភាពរវាងប្រជាជាតិ, ពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ហើយនឹងជួយអភិវឌ្ឍន៍ដល់សកម្មភាពនានារបស់អង្គការសហប្រជាជាតិក្នុងការរក្សាសន្តិភាព ។

៣. មាតាបិតា មានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសនូវប្រភេទនៃការអប់រំសំរាប់បុត្រធីតារបស់គេ ។

## មាត្រា ២៧

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមចំណែកដោយសេរីក្នុងជីវភាពវប្បធម៌របស់សហគមន៍ មានសិទ្ធិត្រេកអរសជាតិនៃសិល្បកម្មទាំងឡាយ និងមានសិទ្ធិរួមចំណែកក្នុងវឌ្ឍភាពនៃវិទ្យាសាស្ត្រ និងគុណប្រយោជន៍ផ្សេងៗ ដែលជាលទ្ធផលចេញពីវឌ្ឍនភាពនេះ ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវកិច្ចការពារដល់ផលប្រយោជន៍ខាងសីលធម៌ និង សម្ភារៈដែលកើតចេញពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈ ដែលខ្លួនជាអ្នកបង្កើត ។

## មាត្រា ២៨

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវរបៀបរៀបរយសង្គម និងរបៀបរៀបរយអន្តរជាតិ ដើម្បីអោយសិទ្ធិនិងសេរីភាពដែលចែងក្នុងសេចក្តីប្រកាសនេះផ្តល់ការយល់ដឹងយ៉ាងពេញលេញទៅបាន។

## មាត្រា ២៩

១. បុគ្គលម្នាក់ៗមានករណីយកិច្ចចំពោះសហគមន៍ដែលជាកន្លែងតែមួយគត់ ដែលអាចបង្កើតនូវការរីកចំរើនពេញបរិបូរណ៍ និងដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២. ក្នុងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតក្នុងការកំណត់ទាំងឡាយ ណាដែលច្បាប់បានកំណត់ក្នុងគោលបំណងឱ្យមានការទទួលស្គាល់ និងគោរពដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃ និងដើម្បីឆ្លើយតបនឹងការតម្រូវយ៉ាងត្រឹមត្រូវអំពីសីលធម៌, របៀបរៀបរយសាធារណៈ និងនៃសុខុមាលភាពទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

៣. ក្នុងករណីណាក៏ដោយ សិទ្ធិនិងសេរីភាពទាំងនោះមិនអាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍របស់សហប្រជាជាតិឡើយ ។

## មាត្រា ៣០

ឥតមានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ ត្រូវបានគេបកស្រាយថា អាចឱ្យរដ្ឋណាមួយក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយ ដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយឆ្ពោះទៅរកការបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុង សេចក្តីប្រកាសនេះឡើយ ។